Capacity Development for Education for All
The CapEFA Programme

United Nations Educational, Scientific and Cultural Organization

សុន្ទរកថា

លោកស្រី អាន ឡឺមៃស្ត្រ តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា

# ពិធីផ្សព្វផ្សាយយុទ្ធនាការអក្ខរកម្មជាតិឆ្នាំ២០១៥

នៅវិទ្យាស្ថានជាតិអប់រំ ថ្ងៃទី ០២ មីនា ២០១៥ ភ្នំពេញ

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងអនុរដ្ឋលេខាធិការ
ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
ឯកឧត្តមឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត
ឯកឧត្តម ភ្ញៀវកិត្តិយស លោក លោកស្រី

ខ្ញុំមានសេចក្តីរីករាយ និងកិត្តិយសក្រៃលែង ដែលបានចូលរួមក្នុងព្រឹត្តិការណ៍នៃការប្រារព្ធពិធីផ្សព្វផ្សាយយុទ្ធនាការអក្ខរកម្មជាតិឆ្នាំ២០១៥ និង ចែករំលែកពាក្យពេចន៍មួយចំនួនជាមួយនឹងអ្នកទាំងអស់គ្នា។ ជាបឋម ខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់កិត្តិយសចូលរួមប្រកាសផ្សព្វផ្សាយយុទ្ធនាការអក្ខរកម្មជាតិនាពេលនេះ។ ខ្ញុំក៏សូមសម្តែងអំណរគុណចំពោះដល់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំពិធីដ៏សំខាន់មួយនេះ។ ហើយខ្ញុំក៏សូមស្វាគមន៍អ្នកទាំងអស់គ្នាដែលបានចូលរួមនៅក្នុងពិធីនេះ។ ជាងនេះទៀត ខ្ញុំសូមសំដែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះអង្គពិធីទាំងមូល ជាពិសេសចំពោះឯកឧត្តម លោក លោកស្រី ដែលអញ្ជើញមកពីតាមបណ្តាខេត្ត-ក្រុង ស្រុក-ខណ្ឌ។

សម្តេច ឯកឧត្តម លោក លោកស្រី

អង្គការយូណេស្កូ និង រាជរដ្ឋាភិបាលកម្ពុជាមានជំនឿថា អក្ខរកម្មរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ អក្ខរកម្មជួយប្រជាជនឲ្យទទួលឱកាសអប់រំ វិទ្យាសាស្ត្រ វប្បធម៌ និងសេដ្ឋកិច្ច ដែលនាំឲ្យមានការអភិវឌ្ឍន៍បុគ្គល សហគមន៍ សង្គម និងប្រទេសជាតិទាំងមូល។ អក្ខរកម្មជួយមនុស្សយល់ដឹងបានកាន់តែប្រសើរឡើង វិភាគពត៌មាន ទទួលបាននូវចំណេះដឹងថ្មីៗ និងបង្កើតឱកាសក្នុងការកែលម្អគុណភាពជីវិត។ ឧទាហរណ៍ មាតាបិតាជាអក្ខរជនអាចផ្តល់បរិយាកាសសិក្សារៀនសូត្រ និងការអប់រំនៅផ្ទះល្អប្រសើរដល់កូនៗ។ យុវជនដែលមានការអប់រំខ្ពស់ទទួលបានការងារល្អ ជាពិសេសស្ត្រី។ ចាប់តាំងពីឆ្នាំ១៩៩០មក អង្គការយូណេស្កូបានផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកែលម្អស្ថានភាពអក្ខរកម្មដល់ពលរដ្ឋគ្រប់រូប។ អង្គការយូណេស្កូមានសេចក្តីរីករាយចូលរួមគាំទ្រនូវរាល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធានាថាការប្តេជ្ញារបស់កម្ពុជាចំពោះគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេសគោលដៅអក្ខរកម្មត្រូវសម្រេចបាននៅឆ្នាំ២០១៥។ លោកស្រី អ៊ីរីណា បូកូវ៉ា អគ្គនាយកអង្គការយូណេស្កូបានថ្លែងសង្ខេបអត្ថន័យអក្ខរកម្មថា "អក្ខរកម្មមិនត្រឹមតែផ្លាស់ប្តូរជីវិតរស់នៅ ប៉ុន្តែថែមទាំងបានជួយគាំពារដល់ពួកគេទៀតផង"។

ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់សម្តេចនាយករដ្ឋមន្ត្រី យើងសង្ឃឹមថាយុទ្ធនាការនេះនឹងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅទូទាំងប្រទេស រួមមាន ក្រសួងស្ថាប័ននានា សង្គមស៊ីវិល វិស័យឯកជន ពលរដ្ឋកម្ពុជា និងសហគមន៍អន្តរជាតិ។ ដើម្បីធានាដល់ការសម្រេចបានផ្លែផ្កានេះ ការគាំទ្រ និងមគ្គុទ្ទេសភាពរបស់សម្តេចនាយករដ្ឋមន្ត្រីនៅក្នុងពិធីនេះ និងសម្រាប់ការអនុវត្តយុទ្ធនាការពិតជាមានសារៈសំខាន់។

សម្តេច ឯកឧត្តម លោក លោកស្រី

ប្រទេសកម្ពុជាបានប្តេជ្ញានៅក្នុងក្របខណ្ឌសេចក្តីថ្លែងការណ៍ស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា (EFA) នាទីក្រុងដាការឆ្នាំ២០០០។ ក្រសួងអប់រំ យុវជន និងកីឡា ដែលជាក្រសួងបង្គោលនៅក្នុងការងារនេះបានធ្វើអោយមានការរីកចម្រើនយ៉ាងខ្លាំងក្នុងការឈានទៅសម្រេចបានគោលដៅ EFA ទាំង៦។ ក្រសួងផែនការបានចេញរបាយការណ៍ថា អត្រាអក្ខរកម្មជនពេញវ័យអាយុ១៥ឆ្នាំឡើង បានកើន១០ភាគរយ ពី៦៧,៣នៅឆ្នាំ១៩៩៨ ទៅ៧៧,៦ភាគរយនៅឆ្នាំ២០០៨។ នៅក្នុងឆ្នាំ២០១៣ អត្រានេះបានបន្តកើនដល់៧៩,៩ភាគរយ។

ដើម្បីសម្រេចបានគោលដៅ EFA អក្ខរកម្មជនពេញវ័យនៅឆ្នាំ២០១៥ វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូបានបង្ហាញថា កម្ពុជាត្រូវសម្រេចអោយបានអត្រាអក្ខរកម្មជនពេញវ័យយ៉ាងតិច ៨៤,៤ភាគរយ។ ក្នុងន័យនេះ ខ្ញុំសូមសំដែងការកោតសរសើរដល់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងសហការីទាំងអស់ ជាពិសេសនាយកដ្ឋានអប់រំក្រៅប្រព័ន្ធដែលបានរៀបចំផែនការពន្លឿនអក្ខរកម្មរបស់ប្រទេសរយៈពេលបីឆ្នាំ ដែលផែនការនេះបានជួយដល់ក្រសួងក្នុងការអនុវត្តយុទ្ធនាការអក្ខរកម្មជាតិឆ្នាំ២០១៥។

ក្រោយពីពិធីប្រកាសផ្សព្វផ្សាយយុទ្ធនាការនេះ ខ្ញុំមានជំនឿថាក្រសួងអប់រំ យុវជន និងកីឡាមានតម្រូវការគាំទ្រ ច្រើនថែមទៀតពីសំណាក់មន្ត្រីទាំងអស់នៅគ្រប់លំដាប់ថ្នាក់ ជាពិសេសមន្ត្រីនៅថ្នាក់ភូមិ និងឃុំ-សង្កាត់ ពីព្រោះពួគគាត់គឺជាអ្នកចុះបញ្ជីឈ្មោះសិស្សអក្ខរកម្មចំនួន៩២១២៥នាក់ ទៅក្នុងថ្នាក់អក្ខរកម្មចំនួន៣៦៨៥ថ្នាក់ ដែលមានទីតាំងនៅជិតផ្ទះក្នុងសហគមន៍របស់ពួកគេ។ អង្គការយូណេស្កូមានក្តីសង្ឃឹមថាសិស្សអក្ខរកម្មទាំងអស់នឹងចាត់ទុកថាការចុះឈ្មោះចូលរៀន និងការបញ្ចប់ការសិក្សាថ្នាក់អក្ខរកម្ម គឺជាការវិនិយោគមួយនៅក្នុងផែនការគ្រួសាររយៈពេលវែងរបស់ពួកគេ។

ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងរៀបចំយុទ្ធសាស្ត្រអនុវត្តយុទ្ធនាការនេះជាមួយនឹងមន្ត្រីពាក់ព័ន្ធ និងអង្គការយូណេស្កូ។ ក្នុងន័យរួមចំណែកដល់ដំណើរការនេះ ខ្ញុំសូមលើកឡើងពីប្រសិទ្ធភាពនៃការពិនិត្យតាមដានដំណើរការថ្នាក់អក្ខរកម្ម ដែលទាមទារអោយមានការចូលរួមគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋានធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡា។ វាជាការចាំបាច់ណាស់ដែលថាក្រសួងអប់រំ យុវជន និងកីឡា ត្រូវកំណត់អោយបានច្បាស់លាស់ពីតួនាទី និងភារកិច្ចទទួលខុសត្រូវ វិសាលភាពនៃការទទួលខុសត្រូវ និងកាលវិភាគនៃដំណើរការពិនិត្យតាមដាន។

នៅក្រោយពីពិធីប្រកាសផ្សព្វផ្សាយយុទ្ធនាការនេះ ខ្ញុំមានជំនឿថាក្រសួងអប់រំ យុវជន និងកីឡា នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដើម្បីដាក់បញ្ចូលសិស្សអក្ខរកម្មទាំងនោះទៅក្នុងក្រុមគោលដៅនៃជំរឿនស្ថិតិប្រជាជនកម្ពុជា ស្តីពីលទ្ធផលនៃការងារអក្ខរកម្ម និងការអប់រំ។

Capacity Development for Education for All
The CapEFA Programme

United Nations Educational, Scientific and Cultural Organization

សម្តេច ឯកឧត្តម លោក លោកស្រី

ខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានផ្តល់អាទិភាពដល់វិស័យអប់រំ ជាពិសេសយុទ្ធនាការអក្ខរកម្មជាតិនាពេលនេះ។ នៅក្នុងឱកាសនេះ ខ្ញុំមានជំនឿថាគ្រូអក្ខរកម្មចំនួន១១២៧នាក់ និងគ្រូបឋមសិក្សាចំនួន២៥៥៨នាក់ បានត្រៀមលក្ខណៈរួចជាស្រេចក្នុងការផ្តល់សេវាថ្នាក់អក្ខរកម្មដល់សិស្សអក្ខរកម្មចំនួន៩២១២៥នាក់ នៅទូទាំងប្រទេស។ អង្គការយូណេស្កូមានមោទនភាពចំពោះលោកគ្រូ-អ្នកគ្រូទាំងនេះ ដែលបានរួមចំណែកនៅក្នុងយុទ្ធនាការនេះ ដើម្បីធ្វើអោយប្រទេសកម្ពុជាក្លាយជាប្រទេសប្រកបដោយអក្ខរភាពខ្ពស់ នៅក្នុងទស្សនទានឆ្ពោះទៅសហគមន៍សេដ្ឋកិច្ចអាស៊ាននាពេលខាងមុខ និងមហិច្ឆិតាក្នុងការក្លាយជាប្រទេសដែលមានចំណូលលើមធ្យមនៅឆ្នាំ២០៣០ និងជាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿននៅឆ្នាំ២០៥០។ នៅក្នុងស្មារតីនេះ អង្គការយូណេស្កូនឹងប្តេជ្ញាបន្តការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដោយបន្តកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាក់ព័ន្ធ និង ដៃគូពាក់ព័ន្ធទាំងអស់ ដើម្បីលើកកម្ពស់គោលដៅនៃការអប់រំនៅកម្ពុជា។ ខ្ញុំក៏សូមយកឱកាសនេះថ្លែងអំណរគុណដល់ម្ចាស់ជំនួយកម្មវិធីអភិវឌ្ឍសមត្ថភាពអប់រំសម្រាប់ទាំងអស់គ្នា (CapEFA) ដូចជាប្រទេសដាណាម៉ាក ហ្វាំងឡង់ អ៊ីតាលី ន័រវេស ស៊ុយអែត និងប្រទេសស្វីស ដែលអាចអោយកម្មវិធី CapEFA នៅកម្ពុជា ជួយដល់រាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីខែឧសភា ឆ្នាំ២០១០ ដល់ខែធ្នូ ឆ្នាំ២០១៥។ សូមថ្លែងអំណរគុណដល់ក្រុមហ៊ុន Smart Axiata ដែលបានរួមចំណែកគាំទ្រដល់ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដើម្បីចូលរួមក្នុងយុទ្ធនាការអក្ខរកម្មជាតិនេះ។

ខ្ញុំទន្ទឹងរង់ចាំស្តាប់ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីនៅក្នុងឱកាសនេះ ហើយសូមគោរពជូនពរសូមអោយយុទ្ធនាការអក្ខរកម្មជាតិឆ្នាំ២០១៥របស់ប្រទេសកម្ពុជាទទួលបានជោគជ័យ។

សូមអរគុណ!